ប្រតិមាព្រះវិស្ណុរកឃើញនៅទួលស្រះព្រះធាតុ ខេត្តកំពង់ស្ពឺ

ទួលស្រះព្រះធាតុ មានទីតាំងស្ថិតនៅភូមិម្រាលធំ ឃុំពោធិម្រាល ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ដែលមានចម្ងាយប្រមាណ ៥០០ម៉ែត្រ ប៉ែកពាយព្យវត្តពោធិម្រាល។ ទួលស្រះព្រះធាតុ គឺជាទីតាំងប្រាសាទបុរាណនៅសម័យមុនអង្គរ ដែលមានប្រាង្គឥដ្ឋចំនួនពីរ តែបានបាក់បែកទាំងស្រុង។ បច្ចុប្បន្ន នៅទីនេះមានតែគ្រឹះប្រាសាទ សំណល់ឥដ្ឋរាយប៉ាយ បំណែកមេទ្វារ និងជើងទម្រថ្មកក់ ប៉ុន្តែ ទីនេះជាកន្លែងរកឃើញប្រតិមាព្រះវិស្ណុសម័យមុនអង្គរមួយអង្គដ៏គួរឱ្យចាប់អារម្មណ៍។ តើប្រតិមាព្រះវិស្ណុរកឃើញនៅទួលស្រះព្រះធាតុនេះ មានប្រវត្តិ និងលក្ខណៈដូចម្តេចខ្លះ?

ព្រះវិស្ណុ គឺជាទេពដ៏សំខាន់មួយក្នុងចំណោមទេពធំៗទាំងបីនៅក្នុងព្រហ្មញ្ញសាសនា ដែលមានតួនាទីគ្រប់គ្រង ថែរក្សាលោក ហើយបុព្វបុរសខ្មែរបានគោរពប្រតិបត្តិយ៉ាងជ្រាលជ្រៅតាំងពីបុរាណកាលមកម្ល៉េះ ពោល គឺយ៉ាងហោចណាស់ក៏ចុងសម័យហ្វូណន នាស.វ.ទី៥ ឬទី៦ដែរ។ ប្រតិមាព្រះវិស្ណុដែលរកឃើញនៅទួលស្រះព្រះធាតុនេះ បានផ្សព្វផ្សាយដំបូងគេបង្អស់ដោយអ្នកស្រាវជ្រាវជនជាតិបារាំង គឺលោក Robert Dalet។ លោកបានទៅដល់ទីនោះជាមួយលោក Henri Parmentier នៅក្នុងឆ្នាំ១៩៣៣ ហើយបានបោះពុម្ពផ្សាយជាអត្ថបទនៅក្នុងឆ្នាំ១៩៣៥ ដែលមានចំណងជើងថា *"Dix-huit mois de recherches archéologiques au Cambodge"* ក្នុងព្រឹត្តិបត្រសាលាបារាំងចុងបូព៌ាប្រទេស លេខ៣៥, ទំព័រ ១១៧ ដល់ ១៤៥។ រីឯ លោក Henri Parmentier ក៏បានចេញផ្សាយអត្ថបទនៅក្នុងឆ្នាំ១៩៣៥ ដូចគ្នាដែរ ដែលមានចំណងជើងថា *"Complément a l'art Khmèr Primitif"* ផ្សាយដោយសាលាបារាំងចុងបូព៌ាប្រទេស។ តាមរយៈការរៀបរាប់និងរូបភាពនៅក្នុងអត្ថបទ បានបង្ហាញឱ្យឃើញថា នៅក្នុងឆ្នាំ១៩៣៣ ប្រតិមាព្រះវិស្ណុនេះគេបានដាក់ផ្អែកទៅនឹងសសរឈើរោងឬសាឡាំមួយ ដែលស្ថិតនៅទីតាំងដើម ហើយស្ថានភាពនៅពេលនោះគឺបាក់បែកឬបាត់បង់នៅចុងព្រះបាទ និងបាក់ប្រអប់ព្រះហស្តខាងក្រោមទាំងពីរ រីឯផ្នែកខាងលើទាំងព្រះសិរទាំងមូល និងព្រះហស្តខាងលើទាំងពីរ រួមជាមួយកេតនកណ្ឌ គឺនៅសភាពល្អប្រសើរនៅឡើយ។ ប៉ុន្តែ រំលងក្រោយពេលលោកទាំងពីរទៅឃើញបន្តិច ក៏មានក្រុមជនទុច្ចរិតលួចកាត់ព្រះសិរប្រតិមាព្រះវិស្ណុនេះយកទៅលក់ដូរនៅរាជធានីភ្នំពេញ។ ពេលនោះ អាជ្ញាធរបារាំងនិងខ្មែរ បានបើកយុទ្ធនាការស៊ើបអង្កេត រហូតឈានដល់ការចាប់ខ្លួនជនបង្កមកផ្តន្ទាទោសតាមច្បាប់

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

នៅរវាងពាក់កណ្តាលទសវត្សរ៍១៩៣០។ នៅក្នុងពេលនោះហើយ ដែលគេបានដឹកជញ្ជូនដងខ្លួនប្រតិមាយកមករក្សាទុកនៅសារមន្ទីរ Albert Sarraut (សារមន្ទីរជាតិកម្ពុជា) ដែលពេលនោះលោក George Groslier ជានាយកសារមន្ទីរ។ នៅឯសារមន្ទីរ គេបានផ្គុំព្រះសិរជាមួយដងខ្លួនប្រតិមាឡើងវិញ ប៉ុន្តែព្រះហស្តខាងលើទាំងពីរ រួមជាមួយកេតនកណ្ឌ គឺខ្យងស័ង្ខខាងឆ្វេង និងកង់ចក្រខាងស្តាំ បានបាត់បង់អស់ទៅហើយ។ ប្រតិមាព្រះវិស្ណុរកឃើញនៅទួលស្រះព្រះជាតុ ខេត្តកំពង់ស្ពឺមួយអង្គនេះ បានរក្សាទុកនិងដាក់តាំងបង្ហាញជូនសាធារណជននៅសារមន្ទីរជាតិកម្ពុជា ចាប់តាំងពីរវាងពាក់កណ្តាលទសវត្សរ៍ ១៩៣០ រហូតមកដល់ចុងទសវត្សរ៍ ២០០០ ទើបគេបន្តបញ្ជូនប្រតិមានេះទៅរក្សាទុកនិងដាក់តាំងបង្ហាញនៅសារមន្ទីរជាតិអង្គរខេត្តសៀមរាបវិញម្តងរហូតមកទល់បច្ចុប្បន្ន (សារមន្ទីរជាតិអង្គរបើកសម្ពោធជាផ្លូវការនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៧)។

ប្រតិមាព្រះវិស្ណុនេះ មានកម្ពស់ ០,៩៨ម៉ែត្រ សាងឡើងអំពីថ្មភក់ មានលេខបញ្ជី ក.1784 ឬ B.340 ជាសិល្បៈខ្មែរ នាដើមរចនាបថសំបូរព្រៃគុក រវាងពាក់កណ្តាលទី១ នៃស.វ.ទី៧។ ប្រតិមានេះពាក់មកុដរាងស៊ីឡាំងខ្ពស់ ព្រះកត្រ្តារាងជ្រុងច្រើន (មិនសូវមូល) ក្នុងទម្រង់ញញឹមស្រាល ថ្ងាសទាប ច្រមុះធំមានខ្នង់ ព្រះនេត្រស្របវែង ចិញ្ចឹមកោងវែង បបូរមាត់ក្រាស់ (តែរាងខ្ចី) ចង្កាស្រួច និងស្វឹកត្រចៀកវែង។ នៅចំហៀងនៃព្រះសិរ បង្ហាញឱ្យឃើញនូវស្នាមបែកនៃធ្នូ ឬជន្ទល់សិល្បករធ្លាក់ភ្ជាប់នៅនឹងកង់ចក្រ និងខ្យងស័ង្ខនៃព្រះហស្តលើទាំងពីរ ដើម្បីជាលំនឹងនៃរូប ហើយវាជាលក្ខណៈទូទៅនៃប្រតិមាសម័យមុនអង្គរ។ ព្រះអង្គឈរត្រង់ ក្នុងទម្រង់ជា **"សមបាទស្ថានក"** ដែលបង្ហាញរូបរាងព្រះកាយមើលទៅហាក់ដូចជារឹងមាំខ្លាំង (កធំ ស្មាបើក ទ្រូងពេញ ខ្នងរាបស្មើ ពោះប៉ោងបែបធម្មជាតិព្រះហស្តមានកម្លាំង) ហើយព្រះហស្តខាងលើទាំងពីរបាក់អស់ និងព្រះហស្តខាងក្រោមទាំងពីរបាក់ផ្នែកខាងចុង ពោល គឺពុំមាននៅសល់កេតនកណ្ឌទាំងបួនឡើយ (កង់ចក្រ ខ្យងស័ង្ខ ដុំមូល ដំបង)។ ប្រតិមានេះ ស្លៀកសំពត់វែងលាត គ្មានក្ងី មានខ្សែក្រវ៉ាត់ចង្កេះ (ត្រង់កណ្តាលបង្ហាញក្បាលខ្សែក្រវ៉ាត់ចង្កេះ) និងមានជាយធ្លាក់ចំកណ្តាលវែងធ្លាក់ទៅក្រោម ហើយលក្ខណៈសំពត់វែងបែបនេះ គេឃើញច្រើនណាស់នៅសម័យមុនអង្គរ ឧទាហរណ៍ ប្រតិមាព្រះវិស្ណុរកឃើញនៅកំពង់ចាមកៅ ព្រះវិស្ណុរកឃើញនៅទួលជុក ជាដើម។ ចំណែកព្រះបាទវិញ មិនបង្ហាញឱ្យឃើញទេដោយសារតែសំពត់វែងបានបាំងជិតទៅហើយ លើកលែងតែប្រអប់ព្រះបាទខាងក្រោមដែលបានបាក់បែក។ ទម្រង់ជាទូទៅបែបនេះ នាំឱ្យលោក Nadine Dalsheimer យល់ថាប្រតិមាព្រះវិស្ណុរកឃើញនៅទួលស្រះព្រះជាតុ ខេត្តកំពង់ស្ពឺ មានទម្រង់ប្រហាក់ប្រហែលប្រតិមាព្រះវិស្ណុដែលរកឃើញនៅទួលកំណប់ ខេត្តកណ្តាល និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធដូចទៅ

នឹងសិល្បៈឥណ្ឌា នាសម័យគុប្ត ជាពិសេស គឺព្រះនេត្រដែលមានរាងស្មើរតែដូចគ្រាប់អាម៉ុន ច្រមុះមានរាងកោង និងបបូរមាត់ខ្ចី។

សរុបជារួមមក ប្រតិមាព្រះវិស្ណុរកឃើញនៅទួលស្រះព្រះជាតុ ខេត្តកំពង់ស្ពឺ ជាបុរាណវត្ថុដ៏មានតម្លៃសិល្បៈខ្ពស់ក្នុងសម័យមុនអង្គរ (ដើមរចនាបថសំបូរព្រៃគុក នាពាក់កណ្តាលទី១ នៃសតវត្សរ៍ទី៧) និងជាកស្តុតាងដ៏រស់រវើកបង្ហាញពីការគោរពប្រណិប័តន៍យ៉ាងជ្រាលជ្រៅចំពោះព្រហ្មញ្ញសាសនា និកាយវៃស្ណវ និងទំនាក់ទំនងឥទ្ធិពលសិល្បៈឥណ្ឌាសម័យគុប្តរួមបញ្ចូលជាមួយសិល្បៈខ្មែរក្នុងតំបន់។ ទោះបីជាប្រតិមានេះធ្លាប់មានការលួច និងការបំផ្លាញពីក្រុមជនទុច្ចរិតក្នុងសម័យអតីតកាលយ៉ាងណាក៏ដោយ ក៏កិច្ចខិតខំប្រឹងប្រែងអភិរក្ស ការជួសជុលតម្លើងឡើងវិញដោយអ្នកជំនាញ នៃអាជ្ញាធរបាំងនិងខ្មែរ បានរក្សាប្រតិមាដ៏មានតម្លៃនេះ សម្រាប់ដាក់តាំងបង្ហាញជូនសាធារណជនឱ្យបានយល់ដឹង។

បញ្ជីឯកសារយោង

Boisselier, J. (1955) *La statuaire khmère et son évolution*. Saigon: École française d'Extrême-Orient (Publications de l'École française d'Extrême-Orient, 37).

Dalet, R. (1935) 'Dix-huit mois de recherches archéologiques au Cambodge', *Bulletin de l'École française d'Extrême-Orient*, 35(1), pp. 117–145.

Dalsheimer, N. (2001) *Les sculptures du Musée national de Phnom Penh: Art du Cambodge ancien.* Paris: École française d'Extrême-Orient / Éditions du Musée Guimet.


Dalsheimer, N. and Manguin, P.-Y. (1998) 'Viṣṇu mitrés de l'Asie du Sud-Est: une réévaluation', *Bulletin de l'École française d'Extrême-Orient*, 85, pp. 87–123.

Dupont, P. (1955) *La statuaire préangkorienne*. Ascona: Artibus Asiae (Supplementum 15).

Garnier, P. (1997) *Le Musée national de Phnom Penh*. Paris: Éditions de l'Amateur.

Parmentier, H. (1935) 'Complément à l'art khmer primitif', *Bulletin de l'École française d'Extrême-Orient*, 35(1), pp. 1–115.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១-២៖ ប្រតិមាព្រះវិស្ណុរកឃើញនៅទួលស្រែព្រះធាតុ ខេត្តកំពង់ស្ពឺ រាង៤ដើមស.វ.ទី៧
(ថតឆ្នាំ១៩៣៣ នៅទីតាំងដើមផ្ទាល់, ប្រភព៖ EFEO)

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣-៤៖ ប្រតិមាព្រះវិស្ណុរកឃើញនៅទួលស្រះព្រះជាតុ ខេត្តកំពង់ស្ពឺ រាង៨ដើមស.វ.ទី៧ កំពុងតម្កល់និង៨តាំង៨បង្ហាញនៅសារមន្ទីរជាតិអង្គរ ថតឆ្នាំ២០២៦ (មើលពីមុខ និង៨ចំហៀង)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៩៖ លម្អិតផ្នែកខាងលើនៃប្រតិមាព្រះវិស្ណុរកឃើញនៅទួលស្រែព្រះធាតុ ខេត្តកំពង់ស្ពឺ
(មើលពីចំហៀង)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៦៖ លម្អិតផ្នែកខាងលើនៃប្រតិមាព្រះវិស្ណុរកឃើញនៅទួលស្រែព្រះជាតុ ខេត្តកំពង់ស្ពឺ

(មើលពីមុខចំ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី